**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០៧ សរ

# សារាចរ
# ស្តីពី
# ការគ្រប់គ្រងវិមានរដ្ឋធម្មនុញ្ញ

ក្នុងឱកាសព្រះរាជពិធីសម្ពោធវិមានរដ្ឋធម្មនុញ្ញ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៤ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គបានប្រោសប្រទានព្រះបរមរាជឱង្ការថា «**វិមានរដ្ឋធម្មនុញ្ញ** គឺជានីតិបូជនីយដ្ឋានដ៏ពិសិដ្ឋតំណាងឱ្យ **និមិត្តរូបនីតិរដ្ឋ** ដែលមាន **រដ្ឋធម្មនុញ្ញ** ជាកំពូលនៃច្បាប់ផងទាំងឡាយនៅព្រះរាជាណាចក្រកម្ពុជាយើង»។

ប្រតិបត្តិតាមព្រះបរមរាជឱង្ការដ៏ខ្ពង់ខ្ពស់បំផុត និងអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ព្រមទាំងអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាននិងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ រាជរដ្ឋាភិបាលសូមណែនាំអំពីការគ្រប់គ្រងវិមានរដ្ឋធម្មនុញ្ញ និងទីតាំងដីរួមទាំងសួនច្បារវិមានរដ្ឋធម្មនុញ្ញ ដូចខាងក្រោម៖

១- ក្រុមប្រឹក្សាធម្មនុញ្ញ គ្រប់គ្រង ថែរក្សា ការពារ អភិរក្ស អភិវឌ្ឍ ជួសជុល និងកែលម្អតួសំណង់ដែលជានីតិបូជនីយដ្ឋានទាំងមូល ទាំងខាងក្នុងនិងខាងក្រៅ រួមទាំងបរិវេណជុំវិញដែលជាបង្គុំនៃសំណង់នីតិបូជនីយដ្ឋាន ដូចមានគំនូសប្លង់ជាឧបសម្ព័ន្ធនៃសារាចរនេះ។ ការសម្អាតអនាម័យ សេវា និងប្រព័ន្ធបំភ្លឺក្នុងបរិវេណខាងក្នុងនៃ «ខេមរសន្តិមូលសាល» ជាទីតាំង ស្តម្ភរដ្ឋធម្មនុញ្ញ ដែលខាងលើមានទម្រតម្កល់ ព្រះសិរមហាព្រហ្ម ជាការគ្រប់គ្រងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

២- រដ្ឋបាលរាជធានីភ្នំពេញ ត្រូវទទួលខុសត្រូវក្នុងការធានាថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ បរិស្ថាន អនាម័យ និងការបំភ្លឺតួសំណង់ដែលជានីតិបូជនីយដ្ឋាននៅផ្នែកខាងក្រៅ និងបរិវេណជុំវិញដែលជាបង្គុំនៃសំណង់នីតិបូជនីយដ្ឋាន ព្រមទាំងថែទាំអំពូលនៅផ្នែកខាងក្រៅនៃតួសំណង់ សួនច្បារ និងបរិវេណជុំវិញ។ ការភ្ជាប់បណ្តាញនិងការប្រើប្រាស់បរិមាណទឹកនិងអគ្គិសនីជាបន្ទុកចំណាយរបស់រដ្ឋបាលរាជធានីភ្នំពេញ។

៣- ក្រុមប្រឹក្សាធម្មនុញ្ញ ចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនូវតួសំណង់ដែលជានីតិបូជនីយដ្ឋានទាំងមូល ទាំងខាងក្នុងនិងខាងក្រៅ រួមទាំងបរិវេណជុំវិញដែលជាបង្គុំនៃសំណង់នីតិបូជនីយដ្ឋាន នៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានគំនូសប្លង់ជាឧបសម្ព័ន្ធនៃសារាចរនេះ។

ចំពោះរដ្ឋបាលរាជធានីភ្នំពេញ ត្រូវចុះទីតាំងដីរួមទាំងសួនច្បារវិមានរដ្ឋធម្មនុញ្ញ ដែលបានចុះបញ្ជីតាម វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២១៣០១០៥-០២១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ នៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលរាជធានីភ្នំពេញ។

៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវសម្របសម្រួលពិនិត្យលើការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនូវតួសំណង់វិមានរដ្ឋធម្មនុញ្ញ និងទីតាំងដីរួមទាំងសួនច្បារវិមានរដ្ឋធម្មនុញ្ញ របស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងពីរ ដូចមានកំណត់ក្នុងចំណុចទី៣ ឱ្យបានត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៥- ចំពោះរបៀបរបបលម្អិតនៃការប្រើប្រាស់និងថែរក្សាស្របតាមកម្មវិធីនៃពិធីបុណ្យជាតិ អន្តរជាតិ និងព្រឹត្តិការណ៍សំខាន់នានានៅទីតាំងវិមានរដ្ឋធម្មនុញ្ញ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ ស្របតាមការពិភាក្សាលើការអនុវត្តជាក់ស្តែងរបស់គ្រប់ភាគីពាក់ព័ន្ធ។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីភ្នំពេញ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ